ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រុមប្រឹក្សារាជសម្បត្តិ

ក្រសួងព្រះបរមរាជវាំង

ករស / សសរ / ១០០៤ / ០០១

រាជធានីភ្នំពេញ , ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៤

## សេចក្តីសម្រេច
## ស្តីពីការជ្រើសរើសព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

## ក្រុមប្រឹក្សារាជសម្បត្តិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១០០៤ / ០០៣ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ ២០០៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ
- បានឃើញកំណត់ហេតុរបស់គណៈកម្មការរៀបចំការបោះឆ្នោតជ្រើសរើស ព្រះមហាក្សត្រថ្មី ចុះថ្ងៃព្រហស្បតិ៍ ១ កើត ខែអស្សុជ ឆ្នាំវក ឆស័ក ព.ស. ២៥៤៨ ត្រូវនឹងថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០០៤

## សម្រេច

ប្រការ ១.- ត្រូវបានជ្រើសរើស សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ជាព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាដែលមានព្រះបរមនាម " ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី " ។

ប្រការ ២.- ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ប្រារព្ធព្រះរាជពិធីសច្ចាប្រណិធាន មុនចូលគ្រងរាជសម្បត្តិ ។

ប្រការ ៣.- ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នតុលាការ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រធានក្រុមប្រឹក្សារាជសម្បត្តិ

ជា ស៊ីម

# ព្រះបរមនាម ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

*****

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី ។

---

" អ្នកបម្រើមាតុភូមិ សាសនា ប្រជាជាតិ និងប្រជារាស្ត្រខ្មែរ
ដោយស្មោះមឹតភក្តិ និងភក្តីភាព ។ មហាក្សត្រ ដែលព្រះពុទ្ធ និង ព្រះឥន្ទ្រ
លោកឧបត្ថម្ភ ។ អ្នកបង្រួបបង្រួមខេមរជនទាំងអស់ ។ អ្នកការពារឯករាជ្យ
បូរណភាពទឹកដី និង សន្តិភាពនៃកម្ពុជា ព្រមទាំងសុភមង្គល សេរីភាព និង
វិបុលភាព នៃប្រជារាស្ត្រខ្មែរ "

---

LE SERVITEUR FIDÈLE ET DÉVOUÉ DE LA PATRIE, DE LA RELIGION, DE LA NATION ET DU PEUPLE KHMERS, LE PROTÉGÉ DU BOUDDHA, D'INDRA. L'UNIFICATEUR DE TOUS LES KHMERS, LE DÉFENSEUR DE L'INDÉPENDANCE, DE L'INTÉGRITÉ TERRITORIALE, DE LA PAIX DU KAMPUCHEA ET DU BONHEUR, DE LA LIBERTÉ ET DE LA PROSPÉRITÉ DU PEUPLE KHMER.